**Embassy of Japan**
**in the Kingdom of Cambodia**

# Press Release

No. 29 PR-18/EoJ

16 May, 2018

## 2018 Spring Conferment of Decoration The Order of the Rising Sun, Gold and Silver Star is conferred to His Excellency Mr. KEO Puth Reasmey, Former Deputy Prime Minister and High Privy Councillor of His Majesty the King of Cambodia

On May 8, 2018, **H.E. Mr. KEO Puth Reasmey**, Former Deputy Prime Minister and High Privy Councillor of His Majesty the King of Cambodia attended the presentation ceremony to receive **The Order of the Rising Sun, Gold and Silver Star** and was given an audience by His Majesty the Emperor at the Imperial Palace in Japan, following the announcement of the 2018 Spring Conferment of Decorations by the Government of Japan on April 29, 2018.

**H.E. Mr. KEO Puth Reasmey**, was among the 140 foreign national recipients of the 2018 Spring Conferment of Decorations, in recognition of His Excellency's contribution to the strengthening of the cooperation and friendly relations between Japan and Cambodia.

Since the year 1986 when **H.E. Mr. KEO Puth Reasmey** joined the National Cambodian Resistance led by HRH Prince Norodom Sihanouk at that time, His Excellency has contributed to the bilateral relationship between Japan and Cambodia from the very beginning of time of the peace negotiation in Cambodia towards the Agreements on a Comprehensive Political Settlement of the Cambodia Conflict in 1991. Our two countries enjoy "Strategic Partnership" nowadays due to his constant devotion to our relationship.

ស្ថានទូតជប៉ុន

ប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

លេខ: 29 PR-18/EoJ

ថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០១៨

## ការប្រគល់គ្រឿងឥស្សរិយយសសម្រាប់និទាឃរដូវឆ្នាំ២០១៨
## The Order of the Rising Sun, Gold and Silver Star
## ជូនឯកឧត្តម  កែវ  ពុទ្ធរស្មី
## អតីតឧបនាយករដ្ឋមន្ត្រី  និងជា
## ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ  នៃព្រះរាជាណាចក្រកម្ពុជា

នៅថ្ងៃទី ៨ ខែឧសភា ឆ្នាំ ២០១៨ **ឯកឧត្តម  កែវ  ពុទ្ធរស្មី** អតីតឧបនាយរដ្ឋមន្ត្រី និងជា ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ  នៃព្រះរាជាណាចក្រកម្ពុជា  បានចូលរួមក្នុងពិធីប្រគល់  និងទទួលគ្រឿងឥស្សរិយយស **The Order of the Rising Sun, Gold and Silver Star** និងត្រូវបានរាជានុញ្ញាតឱ្យចូលគាល់ព្រះចៅអធិរាជនៅឯព្រះបរមរាជវាំងប្រទេសជប៉ុន បន្ទាប់ពីការប្រកាសអំពីការប្រគល់គ្រឿងឥស្សរិយយសសម្រាប់និទាឃរដូវឆ្នាំ ២០១៨ ដោយរដ្ឋាភិបាលជប៉ុននៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១៨។

**ឯកឧត្តម  កែវ  ពុទ្ធរស្មី** ស្ថិតក្នុងចំណោមជនបរទេសចំនួន ១៤០ រូបដែលបានទទួលគ្រឿងឥស្សរិយយសសម្រាប់និទាឃរដូវ  ឆ្នាំ២០១៨  ដើម្បីទទួលស្គាល់ការរួមចំណែករបស់ឯកឧត្តម  ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងជាមិត្តភាពរវាងប្រទេសជប៉ុន និងព្រះរាជាណាចក្រកម្ពុជា ។

ចាប់តាំងពីឆ្នាំ១៩៨៦ ពេលដែល **ឯកឧត្តម  កែវ  ពុទ្ធរស្មី** បានចូលរួមក្នុងក្រុមអ្នកតស៊ូជាតិកម្ពុជាដឹកនាំដោយព្រះអង្គម្ចាស់  នរោត្តម  សីហនុ  នៅពេលនោះ  ឯកឧត្តមបានរួមចំណែកលើកតម្កើងទំនាក់ទំនងទ្វេភាគីរវាងប្រទេសជប៉ុន  និងកម្ពុជាតាំងពីការចាប់ផ្តើមដំបូង  នៃការចរចាសន្តិភាពនៅកម្ពុជាឆ្ពោះទៅកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយដ៏ទូលំទូលាយមួយនូវជំលោះនៃប្រទេសកម្ពុជា  នៅឆ្នាំ១៩៩១  ។ ប្រទេសរបស់យើងទាំងពីរបានឈានដល់ "ភាពជាដៃគូយុទ្ធសាស្ត្រ" នាពេលបច្ចុប្បន្ន អាស្រ័យដោយការលះបង់ឥតឈប់ឈររបស់ឯកឧត្តមចំពោះទំនាក់ទំនងរបស់យើង ។

ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: ០២៣-២១៧ ១៦១    ទូរសារ: ០២៣-២១៦ ១៦២